ប្រការ ២ : អនុញ្ញាតអោយក្រុមហ៊ុន ងីម គីមឡេង អភិវឌ្ឍន៍ពាណិជ្ជ (NGIM KIM LENG DEVELOPMENT TRADING CO.,LTD) ទទួលបន្ទុកក្នុងការសាងសង់ថ្មី និងការជួសជុលអាគាររដ្ឋបាល អាគារសិក្សាធំ-តូច ទាំងអស់ ជួសជុលបន្ទប់ពិសោធន៍ សាងសង់អាគារពិសោធន៍ ជួសជុលអាគារសិក្សា សាងសង់អាគារសិក្សា និងអន្តេវាសិកដ្ឋាន នៅតាមសាលារៀនចំណេះទូទៅ តាមសាលាគរុកោសល្យ វិក្រឹត្យការខេត្ត-ក្រុង និង មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងរាល់សំណង់ទាំងអស់ជូនក្រសួងអប់រំ យុវជន និងកីឡា សំរាប់ ឆ្នាំ២០០០ ដល់ឆ្នាំ ២០០៣ ដោយប្រើប្រាស់ថវិកាជំពូក ១១ ជំពូក៥០.០១ ជំពូក៥០.០២ និងថវិកាជាតិត្រៀម បំរុងផ្សេងៗទៀត ។

ប្រការ ៣ : ចំពោះថ្លៃនៃការផ្គត់ផ្គង់ ទុព្វលភារៈ សំភារៈបរិក្ខារ និងការជួសជុលសាងសង់ទាំងអស់ដូចមានចែងក្នុង ប្រការ១ និងប្រការ២ ក្រសួងអប់រំ យុវជន និងកីឡា រួមជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវធ្វើការ ពិគ្រោះថ្លៃ ជាមួយក្រុមហ៊ុន ណារី ឃ្លាំមិន អេន ត្រេដឌីង និងក្រុមហ៊ុន ងីម គីមឡេង អភិវឌ្ឍន៍ពាណិជ្ជ អោយ បានសមស្រប និងពិនិត្យគុណភាពអោយបានច្បាស់លាស់ ។

ប្រការ ៤ : ចំពោះការផ្គត់ផ្គង់ ទុព្វលភារៈ សំភារៈបរិក្ខារ និងការជួសជុលសាងសង់ទាំងអស់ដូចមានចែងក្នុងប្រការ១ និងប្រការ២ ក្រុមហ៊ុនត្រូវធ្វើការផ្គត់ផ្គង់ និងជួសជុលសាងសង់ជូនមុន ហើយទូទាត់ជាក្រោយជាដំបាក់ៗ តាមថវិការដ្ឋដែលមាន ។

ប្រការ ៥ : រាល់លិខិតបទដ្ឋានទាំងឡាយ ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៦ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

• រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០០

## សេចក្តីសំរេចលេខ ០៦ សសរ

## ស្តីពី ការបង្កើតគណៈកម្មការដោះស្រាយទំនាស់ដែនឡូត៍នេសាទ ជាមួយប្រជាជននៅស្រុកឯកភ្នំ ខេត្តបាត់ដំបង

***

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមការងារចាំបាច់ និងបន្ទាន់របស់រាជរដ្ឋាភិបាល

**សំរេច**

ប្រការ ១ : បង្កើតគណៈកម្មការដោះស្រាយទំនាស់ដែនឡូតិ៍នេសាទ ជាមួយប្រជាជននៅស្រុកឯកភ្នំ ខេត្តបាត់ដំបង ដែល មានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| ១-តំណាង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| ២-តំណាង ក្រសួង មហាផ្ទៃ | អនុប្រធាន |
| ៣-តំណាង ក្រសួង ការពារជាតិ | សមាជិក |
| ៤-តំណាង ក្រសួង ធនធានទឹក និងឧតុនិយម | សមាជិក |
| ៥-តំណាង ក្រសួង រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៦-តំណាង ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧-តំណាង អភិបាលខេត្តបាត់ដំបង | សមាជិក |
| ៨-តំណាង នាយកដ្ឋានជលផល | លេខាធិការ |

ប្រការ ២ .-គណៈកម្មការនេះមានភារកិច្ច :

១-ចុះត្រួតពិនិត្យ និងស្រាវជ្រាវអោយបានច្បាស់លាស់ អំពី :

-លក្ខណៈភូមិសាស្ត្រនៃព្រំប្រទល់ដែនឡូតិ៍នេសាទនីមួយៗ

-ចំនួនបឹងដែលមានភូមិសាស្ត្រនៅក្បែរ និងជាប់ភូមិ ឃុំ

-ឈ្មោះបឹង ទីតាំងបឹង ទំហំបឹង ការប៉ាន់ប្រមាណត្រីក្នុងបឹងនីមួយៗ ដើម្បីងាយស្រួលដល់ជីវភាពរស់នៅរបស់ប្រជាជនក្នុងភូមិសាស្ត្រនោះ និងក៏ងាយស្រួលដល់រដ្ឋក្នុងការដាក់ឡូតិ៍នេសាទអោយដេញថ្លៃ។

២-ធ្វើរបាយការណ៍លំអិតអំពីលទ្ធផលត្រួតពិនិត្យ និងលើកវិធានការដោះស្រាយដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសំរេច ។

ប្រការ ៣ : សមាជិកគណៈកម្មការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

ប្រការ ៤ : បទបញ្ញត្តិទាំងឡាយណាដែល ដែលផ្ទុយពីសេចក្តីសំរេចនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៦ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ

នៃបណ្ដាក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តបាត់ដំបង និងសាមីភាព ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្ដីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ.នាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ស ខេង

★★★

រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០០

## សេចក្ដីសម្រេចលេខ ០៧ សសរ

## ស្ដីពី ការបង្កើតគណៈកម្មការ វិទ្យាសាស្ត្រ និង បច្ចេកទេសរបស់ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញអនុក្រឹត្យលេខ៥៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្ដីពីការកែសម្រួល ការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

-យោងតាមសំណូមពរការងារចាំបាច់

## សម្រេច

**ប្រការ ១ :** បង្កើតគណៈកម្មការវិទ្យាសាស្ត្រ និងបច្ចេកទេស ហៅកាត់ " គ.វ.ប ឬ S.T.C" របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម ពៅ សាមី | អគ្គលេខាធិការ គ.ជ.គ.ម | ប្រធាន |
| ២-ឯកឧត្តម ផាន់ ខុន | អគ្គលេខាធិការ គ.ជ.គ.ម | អនុប្រធាន |
| ៣-ឯកឧត្តម អ៊ុក ដាមរី | អនុប្រធានទី១ កាកបាទក្រហមកម្ពុជា | អនុប្រធាន |
| ៤-លោក ចាន់ ម៉ុណ្ណារ៉ាត់ | អគ្គនាយករងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | សមាជិក |